ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុបលទ្ធផលការងារ
# អាជ្ញាធរទន្លេសាប
# ប្រចាំឆ្នាំ២០២៥ និងទិសដៅអនុវត្តឆ្នាំ២០២៦



ខែ មីនា ឆ្នាំ ២០២៦

# មាតិកា


**១. សេចក្តីផ្តើម** ..... ១

**២. ចក្ខុវិស័យ បេសកកម្ម និងតួនាទីភារកិច្ចអាជ្ញាធរទន្លេសាប** ..... ២

**៣. ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប** ..... ៣

**៣.១ ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២៤-២០២៨** ..... ៣

**៣.២ ផែនការសកម្មភាពអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ២០២៥** ..... ៣

**៣.៣ ផែនការសកម្មភាពអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ២០២៦** ..... ៤

**៤. វឌ្ឍនភាពការងារ និងលទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៥** ..... ៤

**៤.១ លទ្ធផលការងារ** ..... ៤

**៤.១.១ ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ** ..... ៤

ក. ការងាររដ្ឋបាល ..... ៤

ខ. ការងារគ្រប់គ្រងបុគ្គលិក ..... ៥

គ. ការងារបណ្តុះបណ្តាល ក្នុង និងក្រៅប្រទេស ..... ៥

ឃ. ការងារគ្រប់គ្រងហិរញ្ញវត្ថុ ..... ៦

**៤.១.២ ការងារកិច្ចសហប្រតិបត្តិការ** ..... ៧

ក. ការងារចុះទស្សនកិច្ចសិក្សា ..... ៧

ខ. កិច្ចប្រជុំពិគ្រោះយោបល់ក្នុងប្រទេស ..... ៧

គ. កិច្ចប្រជុំពិគ្រោះយោបល់ក្រៅប្រទេស ..... ១០

**៤.១.៣ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន** ..... ១១

**៤.១.៤ គម្រោងការតាមដានផលចាប់នៅខេត្តជុំវិញបឹងទន្លេសាប** ..... ១១

**៤.១.៥ គម្រោងសហប្រតិបត្តិការជាមួយធនាគារពិភពលោក (WB) ស្តីពីការវាយតម្លៃ សន្តិសុខទឹកក្នុងអាងទន្លេសាប** ..... ១២

**៤.១.៦ ការងារបច្ចេកទេសសិក្សាស្រាវជ្រាវ** ..... ១៣

**៤.១.៧ ការងារគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន** ..... ១៤

ក. ការងារគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ..... ១៤

ខ. ការងារគ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មាន ..... ១៥

១. ការងារផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល ..... ១៥

២. ការងារផ្សព្វផ្សាយដល់អាជ្ញាធរមូលដ្ឋាន ..... ១៦

**៤.២ ការងារចំពោះមុខ** ..... ១៦

**៤.២.១ ការងារចុះផ្សៀងផ្ទាត់និយាមកា និងបោះបង្គោលព្រំការពារដីភាត់ផ្សៀល** ..... ១៦

ក. ការងារផ្ទៀងផ្ទាត់ទិន្នន័យ និងកំណត់និយាមកា ..... ១៦
ខ. ការងារសាងសង់បង្គោលកាត់ផ្ទៀល ..... ១៧
គ. សកម្មភាពចុះពិនិត្យវាយតម្លៃ និងប្រគល់ទទួល ការងារបោះបង្គោលព្រំកាត់ផ្ទៀល ..... ១៧
ឃ. ការងារអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក ..... ១៨
ង. ការងារចុះពិនិត្យស្ថានភាពទឹកជំនន់តាមបណ្តាស្ទឹងសំខាន់ៗ ជុំវិញបឹងទន្លេសាប ..... ១៨
ច. ការងារចុះសម្របសម្រួលពាក់ព័ន្ធ និងបញ្ហាក្នុងបឹងទន្លេសាប ..... ១៩
**៤.២.២ ការងារពិនិត្យផ្ទៀងផ្ទាត់ធ្វើបច្ចុប្បន្នភាព និងរចនាក្រុមទិន្នន័យដីធ្លី ..... ២១**
ក. ការងារចុះសហការជាមួយក្រសួងស្ថាប័ន អាជ្ញាធរដែនដី និងមន្ទីរពាក់ព័ន្ធ ..... ២១
ខ. ការងារចុះធ្វើបច្ចុប្បន្នភាពប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម តំបន់បឹងទន្លេសាប ..... ២១
**៤.៣ ការវិភាគមុខងារ និងរចនាសម្ព័ន្ធស្ថាប័ន ..... ២២**
**៥. បញ្ហាប្រឈម ..... ២២**
**៦. សន្និដ្ឋាន និងទិសដៅការងារបន្ត ..... ២៣**

## ១. សេចក្តីផ្តើម

អាជ្ញាធរទន្លេសាប គឺជាស្ថាប័នមួយមានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល ត្រូវបានបង្កើតឡើងតាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ និងព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩។ រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត **"យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១"** ដើម្បី **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** និងការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់បន្តដំណើរឈានទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក៏ដូចជាការបន្តពង្រឹងសមត្ថភាព អភិបាលកិច្ច និងគុណភាពរបស់ស្ថាប័ន រួមជាមួយការធានាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ការចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រខាងលើនេះ អាជ្ញាធរទន្លេសាប បានជំរុញការយកចិត្តទុកដាក់ដោយហ្មត់ចត់ ក្នុងស្មារតីពង្រឹងនូវបេសកកម្មការងារ តួនាទី និងភារកិច្ច ការទទួលខុសត្រូវក្នុងនាមជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាល លើការសម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការដាក់ចេញនូវវិធានការការពារ ថែរក្សា និងទប់ស្កាត់រាល់បទល្មើសដែលធ្វើឱ្យបាត់បង់ធនធានធម្មជាតិ បរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់បឹងទន្លេសាប រួមជាមួយការធ្វើកំណែទម្រង់ច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រប្រកបដោយភាពម៉ឺងម៉ាត់ និងហ្មត់ចត់ គឺសំដៅជំរុញការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងការបំពេញតួនាទីភារកិច្ច និងការទទួលខុសត្រូវជាមួយនឹងការកំណត់បាននូវកម្មវិធីបេសកកម្មការងារស្នូលរបស់ស្ថាប័ន (១). លើកកម្ពស់កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងប្រជាជននៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ (២). លើកកម្ពស់កិច្ចការការពារ និងថែរក្សាធនធានធម្មជាតិ និងបរិស្ថាន ដើម្បីធានាដល់គុណភាពធនធានធម្មជាតិ និងបរិស្ថាន និង(៣). សម្របសម្រួលរាល់គម្រោងដែលបាន និងកំពុងអនុវត្តនៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ។ អាជ្ញាធរទន្លេសាប បានកំណត់នូវចក្ខុវិស័យ គោលដៅ និងទិសដៅយុទ្ធសាស្ត្ររបស់ស្ថាប័ននៅក្នុងផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ និងយកចិត្តទុកដាក់ពង្រឹងការអនុវត្តរាល់សកម្មភាពជាយុទ្ធសាស្ត្រ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ និងបានដាក់ចេញនូវសកម្មភាពការងារលម្អិតប្រចាំឆ្នាំក្នុងផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ក្នុងការជំរុញប្រសិទ្ធភាពការងាររបស់ស្ថាប័ន និងចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។

## ២. ចក្ខុវិស័យ បេសកកម្ម និងតួនាទីភារកិច្ចអាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប គឺជាស្ថាប័នមួយដើរតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងចំណោមបណ្តាក្រសួង-ស្ថាប័ន ដែលជាសមាជិកត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ និងព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩។

អាណត្តិការងាររបស់អាជ្ញាធរទន្លេសាប "**សម្របសម្រួល ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប**" ដែលអាណត្តិការងារ ក៏បានបញ្ជាក់ពីការងារជាអាទិភាព គឺផ្តោតលើ៖

- សម្របសម្រួលរាល់សកម្មភាពមកលើធនធានធម្មជាតិ ការពារ និងថែរក្សាបរិស្ថាន និងជីវវូបសាស្ត្រនៃបឹងទន្លេសាប
- សម្របសម្រួលរាល់កម្មវិធី និងសកម្មភាពសង្គមកិច្ច សេដ្ឋកិច្ច រួមជាមួយនឹងទិសដៅកាត់បន្ថយភាពក្រីក្រនៅតំបន់ទន្លេសាប និងលើកកម្ពស់ការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន

**ចក្ខុវិស័យ**

អាជ្ញាធរទន្លេសាប ជាស្ថាប័នប្រកបដោយឧត្តមភាពការងារ ក្នុងការសម្របសម្រួលដល់ការគ្រប់គ្រងធនធានទឹក ធនធានធម្មជាតិ និងបរិស្ថានតំបន់ទន្លេសាប ។

**បេសកកម្ម**

សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយចីរភាព ។

ព្រះរាជក្រឹត្យ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប ក៏បានកំណត់ច្បាស់ពីតួនាទីចម្បងរបស់អាជ្ញាធរទន្លេសាប គឺពង្រឹងនូវការសម្របសម្រួលនៅតំបន់ទន្លេសាប ដោយតាមដានត្រួតពិនិត្យ និងវាយតម្លៃ នូវរាល់គម្រោង និងសកម្មភាពនានា។ ក្នុងមាត្រាទី៤ នៃព្រះរាជក្រឹត្យ ក៏ដូចជាខ្លឹមសារដែលបានចែងនៅក្នុងអនុក្រឹត្យផងដែរ អាជ្ញាធរទន្លេសាប មានតួនាទីដោយផ្តោតទៅនឹងគម្រោង ដូចខាងក្រោម ៖

១ ជាស្ថាប័នសិក្សាស្រាវជ្រាវ តាមដាន និងវាយតម្លៃ អំពីសក្តានុពល សេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ដើម្បីរៀបចំផែនការមេ ទស្សនវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ សម្រាប់ដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច

២ ជាដៃគូ ជួយសម្របសម្រួលក្នុងដំណើការគម្រោង ដែលគួរបន្តអនុវត្តក្នុងតំបន់ទន្លេសាប

៣ តាមដានត្រួតពិនិត្យការអនុវត្តន៍គម្រោងកំពុងអនុវត្ត ដើម្បីធានាការអនុវត្តបានបំពេញទៅដល់ទិសដៅ និងកម្មវិធីនៃការអនុវត្ត

៤ វាយតម្លៃការអនុវត្តគម្រោង ដែលត្រូវបានបញ្ចប់ ដើម្បីពិនិត្យពីភាពជោគជ័យរបស់គម្រោងជាមួយនឹងគោលដៅដែលចង់បាន

# ៣. ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប

## ៣.១ ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២៤-២០២៨

ការកំណត់បាននូវក្របខ័ណ្ឌស្នូលនៃផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ត្រូវបានផ្តួចផ្តើមគំនិតក្នុងការរៀបចំឡើង ដោយការប្រមូលផ្តុំរាល់គំនិតយោបល់ ដែលជាធាតុចូលយ៉ាងសំខាន់ៗ ពីកម្រិតថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធ និងបានទទួលការឯកភាពដោយអាជ្ញាធរទន្លេសាប ដើម្បីឲ្យស្របជាមួយតួនាទីភារកិច្ច និងការទទួលខុសត្រូវដូចបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តស្តីពីការបង្កើតអាជ្ញាធរទន្លេសាប។ ជាពិសេស ក្នុងស្មារតីយកចិត្តទុកដាក់ និងចូលរួមគាំទ្រដល់ដំណើរការអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ដែលបានកំណត់ និងដាក់ចេញឱ្យអនុវត្តក្នុងគោលនយោបាយយុទ្ធសាស្ត្រ បញ្ចកោណដំណាក់កាលទី ១។




១. អភិវឌ្ឍន៍ព័ត៌មាន និងទិន្នន័យឲ្យកាន់តែប្រសើរឡើង អំពីតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

២. លើកកម្ពស់ការយល់ដឹង អប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាល

៣. ពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធរបស់អាជ្ញាធរទន្លេសាប

៤. លើកកម្ពស់សមត្ថភាព និងពង្រឹងការគ្រប់គ្រងស្ថាប័នរបស់អាជ្ញាធរទន្លេសាប និងក្រសួង/ស្ថាប័នពាក់ព័ន្ធ

៥. លើកកម្ពស់ និងអភិវឌ្ឍន៍ ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានឌីជីថល។

## ៣.២ ផែនការសកម្មភាពអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ២០២៥

ផែនការសកម្មភាពការងារឆ្នាំ២០២៥ របស់អាជ្ញាធរទន្លេសាប គឺជាសកម្មភាពការងារលម្អិតសម្រាប់ប្រតិបត្តិការការងារជាក់ស្តែង ដោយមានការចូលរួមសហការពីបណ្តាក្រសួង-ស្ថាប័នទាំងក្នុងកម្រិត ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ សង្គមស៊ីវិល អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជម្រុញប្រសិទ្ធភាព នៃការអនុវត្តផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល ៥ឆ្នាំ (២០២៤-២០២៨) ឱ្យទទួលបានជោគជ័យ។

ជារួម ផែនការសកម្មភាពការងារត្រូវបានរៀបចំឡើងដោយបន្សីជាមួយគម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ នៃផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ របស់អាជ្ញាធរទន្លេសាប(២០២៤-២០២៨)។ ជាពិសេស ស្របទៅតាមតួនាទីភារកិច្ចការងារទទួលខុសត្រូវ ដូចបានកំណត់ក្នុងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងគាំទ្រដល់បេសកកម្មការងារ។



## ៣.៣ ផែនការសកម្មភាពអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ២០២៦




ផ្អែកលើសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ កន្លងមក អាជ្ញាធរទន្លេសាប បានធ្វើការវាយតម្លៃដោយយកចិត្តទុកដាក់បំផុតលើភាពខ្លាំង និងបញ្ហាប្រឈម ដែលតម្រូវឱ្យបន្តដោះស្រាយដោយភាពហ្មត់ចត់ នៅដំណាក់កាលបន្ទាប់ ក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាព ឆ្នាំ២០២៦ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដោយអនុលោមតាមស្មារតីនៃបេសកកម្មការងារក្នុងការសម្របសម្រួល ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ តំបន់ទន្លេសាប ប្រកបដោយចីរភាព។ ជាពិសេស ចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី៧ **ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** សំដៅការពារ ថែរក្សា និងពូនជ្រំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ផែនការសកម្មភាពការងារឆ្នាំ២០២៦ មានចំនួន ១៧សកម្មភាព ដែលសកម្មភាពទាំងនោះ ស្ថិតក្នុងសកម្មភាពយុទ្ធសាស្ត្រ ទិសដៅយុទ្ធសាស្ត្រ និងគោលដៅយុទ្ធសាស្ត្រ នៃផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល៥ឆ្នាំ (២០២៤-២០២៨)។

# ៤. វឌ្ឍនភាពការងារ និងលទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៥

## ៤.១ លទ្ធផលការងារ

### ៤.១.១ ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

#### ក. ការងាររដ្ឋបាល

- ទទួលបានលិខិតចូលចំនួន ១៤៩ច្បាប់ លិខិតចូលក្រៅប្រទេសចំនួន ១៤ច្បាប់ លិខិតចូលផ្ទៃក្នុង ៦១៦ច្បាប់ លិខិតចេញចំនួន ៥៤៧ច្បាប់ និងលិខិតចេញផ្ទៃក្នុងចំនួន ១៤៣ច្បាប់
- រៀបចំតាក់តែងលិខិតរដ្ឋបាល សម្របសម្រួលសេវារដ្ឋបាល និងកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងអង្គភាព
- បានសរុបរបាយការណ៍រួមរបស់ អ.ទ.ស ប្រចាំខែ ត្រីមាស ឆមាសទី ប្រចាំឆ្នាំ និងទិសដៅអនុវត្តបន្ត
- បានសហការរៀបចំកិច្ចប្រជុំបានចំនួន ៥០លើក
- បានរៀបចំសម្របសម្រួលកិច្ចប្រជុំនានា សិក្ខាសាលា វគ្គបណ្តុះបណ្តាលផ្សេងនៅក្នុងអង្គភាព
- បានរៀបចំ និងរក្សាទុកនូវរាល់ឯកសារ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ទាក់ទងនឹង អ.ទ.ស
- បានគ្រប់គ្រង ថែទាំ និងជួសជុលបណ្តាញទឹក ភ្លើង អ៊ីនធឺណិត ម៉ាស៊ីន Printer Copy ជាប្រចាំ
- បានចាត់ចែងការងារ សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងបរិវេណអង្គភាពជាប្រចាំ
- បានរៀបចំផ្គត់ផ្គង់ទឹកបរិសុទ្ធ និងភេសជ្ជៈ ប្រចាំខែ ជូនថ្នាក់ដឹកនាំ និងនាយកដ្ឋានទាំង៤ ក្រោមឱវាទអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប
- បានសម្របសម្រួលនូវរាល់ឯកសារពាក់ព័ន្ធ ជូនថ្នាក់ដឹកនាំ និងមន្ត្រីនៅអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប និងក្រសួង/ស្ថាប័នពាក់ព័ន្ធ
- បានរៀបចំ ថែទាំ ជួសជុលរថយន្ត និងសម្ភារៈបរិក្ខាបច្ចេកទេស ដែលប្រើប្រាស់នៅអាជ្ញាធរទន្លេសាបជាប្រចាំ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋាន និងថ្នាក់ដឹកនាំប្រគល់ជូន។

## ខ. ការងារគ្រប់គ្រងបុគ្គលិក

- ឆ្នាំ២០២៥នេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប សរុបចំនួន៩៩ រូប (ស្រី ១៤រូប) និងមន្ត្រីជាប់កិច្ចសន្យាចំនួន ២៩រូប(ស្រី ០៥រូប)
- បានរៀបចំបូកសរុបបញ្ជីវត្តមានប្រចាំខែរបស់ការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល
- បានបូកសរុបស្ថិតិ មន្ត្រីរាជការ អ.ទ.ស
- បានរៀបចំបូកសរុបបញ្ជីវត្តមានប្រចាំខែរបស់អគ្គលេខាធិការដ្ឋាន អ.ទ.ស ផ្ញើជូនក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងមុខងារសាធារណៈ
- បានរៀបសំណុំឯកសារ ស្តីពីការបន្តប្រើប្រាស់ និងជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា សម្រាប់ អ.ទ.ស ចំនួន ២៩នាក់ ក្នុងឆ្នាំ២០២៥
- បានទទួលរៀបចំដំឡើងថ្នាក់តាមវេនអតីតភាពការងាររបស់មន្ត្រីរាជការ អ.ទ.ស ជូនទៅក្រសួងមុខងារសារធារណៈ ចំនួន ៣៩នាក់
- បានរៀបចំឯកសារពាក់ព័ន្ធ ដើម្បីធ្វើប្រកាសផ្ទេរឈ្មោះមន្ត្រីរាជការ អ.ទ.ស ចំនួន ០១រូប ដែលបានផ្ទេរទីកន្លែងការងារទៅមន្ទីរធនធានទឹក និងឧតុនិយមខេត្តបន្ទាយមានជ័យ
- កំពុងធ្វើបច្ចុប្បន្នភាពបញ្ចូលទិន្នន័យប្រវត្តិរូបមន្ត្រីរាជការ របស់អាជ្ញាធរទន្លេសាប ក្នុងប្រព័ន្ធ HR MIS តាមការណែនាំរបស់ក្រសួងមុខងារសារធារណៈ
- បានរៀបចំឯកសារស្នើសុំ និងបានបោះពុម្ពប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការ ជូនថ្នាក់ដឹកនាំ និងមន្ត្រី អ.ទ.ស
- បានរៀបចំ និងសហការជាមួយក្រសួង ធ.ទ.ឧ ដើម្បីធ្វើបច្ចុប្បន្នភាពប័ណ្ណសមាជិក ប.ស.ស ជូនថ្នាក់ដឹកនាំ និងមន្ត្រី អ.ទ.ស
- រៀបចំលិខិតបេសកកម្មចេញក្នុងប្រទេសមានចំនួន ២២២លេខ។

## គ. ការងារបណ្តុះបណ្តាល ក្នុង និងក្រៅប្រទេស



- វគ្គបណ្តុះបណ្តាលស្តីពី វិជ្ជាជីវៈលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាម FMIS សម្រាប់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញថ្នាក់កណ្តាលបន្ថែមថ្មី នៃក្រសួង-ស្ថាប័នចំនួន៦ និងអ្នកប្រើប្រាស់ថ្មីទៅតាមការដ្ឋាន
- ចូលរួមសង្កេតការពីដំណើរជំរឿនមន្ត្រីរាជការនៅក្រសួងមុខងារសារធារណៈ



- បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលបច្ចេកទេស ស្តីពីការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌគាំទ្រការសម្រេចចិត្ត (Decision Support Framework-DSF) នៅខេត្តកំពង់ឆ្នាំង
- មន្ត្រីបច្ចេកទេសវ័យក្មេង អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប រួមជាមួយនិស្សិតកម្មសិក្សាមកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ទទួលបានការបណ្តុះបណ្តាលចំណេះដឹងពង្រឹងសមត្ថភាពបន្ថែម ដោយអ្នកជំនាញម៉ូឌែល លោកបណ្ឌិត លី ស្ទីវិន អំពីការប្រើប្រាស់ម៉ូឌែល Rainfall-Runoff-Inundation (RRI-Model)

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការបន្សាំ នឹងប្រព័ន្ធអេកូឡូស៊ីទៅក្នុងគោលនយោបាយ ដើម្បីពង្រឹងសមភាពយេនឌ័រនៅក្នុងមហាអនុតំបន់មេគង្គ" Ecosystem-Based Adaptation into policy to Strengthen Gender Equality in the Greater Mekong Subregion " នៅសណ្ឋាគារ Crown Plaza នៅទីក្រុងវៀងចន្ទ ប្រទេសឡាវ
- វគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងទឹកជំនន់ ការព្រមានជាមុន ការព្យាករអាកាសធាតុ និងការតាមដានរបបជលសាស្ត្រ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ នៅសាធារណរដ្ឋប្រជាមានិតចិន
- សិក្ខាសាលាថ្នាក់តំបន់ស្តីពី ផ្ទាំងបង្ហាញ (Dashboard) ការតាមដានភាពសម្បូរត្រី និងភាពចម្រុះប្រភេទត្រី របស់គណៈកម្មការទន្លេមេគង្គ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។





## ឃ. ការងារគ្រប់គ្រងហិរញ្ញវត្ថុ

- បានអនុវត្តនីតិវិធីកិច្ចលទ្ធកម្មចប់ជាស្ថាពរចំនួន ១០គម្រោង (ទំនិញ៨ សំណង់១ សេវាកម្ម១)
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់នីតិវិធីអនុវត្តកិច្ចលទ្ធកម្មសាធារណៈ (ព្រាងអនុក្រឹត្យ ប្រកាស...)
- បានរៀបចំរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស របាយការណ៍ប៉ាន់ស្មានប្រចាំឆ្នាំ និងបានផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៦ និងបានដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុម័ត
- បានរៀបចំផែនការថវិកាឆ្នាំ និងវិភាជន៍តាមមុខសញ្ញាចំណាយនីមួយៗ
- បានផ្គត់ផ្គង់សម្ភារបរិក្ខារ ព័ត៌មានវិទ្យា មិនមែនព័ត៌មានវិទ្យា សង្ហារិម ការិយាល័យ ប្រេងឥន្ធនៈ ......
- បានធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតារាងប្រៀបធៀបសម្ភារ (កើន ថយ)ប្រចាំឆ្នាំ ២០២៥
- បានរៀបចំឯកសារទូទាត់ចំណាយបន្ទាន់ និងប្រចាំក្នុងអង្គភាព( ទឹក អាហារសម្រន់ កាហ្វេ និងជួសជុលថែទាំផ្សេងៗ...)
- បានទំនាក់ទំនងជាប្រចាំជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិនៃកម្ពុជា ដើម្បីដំណើរការឯកសារ
- បានរៀបចំឯកសារទូទាត់ថ្លៃប្រើប្រាស់សេវាអ៊ីនធឺណិត អគ្គិសនី ទឹក ឆ្នាំ២០២៥
- បានរៀបចំឯកសារទូទាត់ (សក្ខីប័ត្រចំណាយ) រដ្ឋទេយ្យបុរេប្រទានចំនួន ៤ជុំបង្វិល
- បានរៀបចំឯកសារទូទាត់ប្រាក់បេសកកម្មចំនួន ៦លើក និងរៀបចំប្រាក់បេសកកម្មបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីរាជការ អ.ទ.ស តាមប្រព័ន្ធធនាគារ
- បានរៀបចំរបាយការណ៍ និងកិច្ចញ្ញត្តិការគណនេយ្យ និងផ្ញើជូនអគ្គនាយកដ្ឋានរតនាគារជាតិ (ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ)
- បានសហការ និងរៀបចំកសាងឯកសារគម្រោងថវិកាឆ្នាំ២០២៦ (ទាំងកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំ)
- បានរៀបចំរបាយការណ៍ចំណូល-ចំណាយ (ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ)
- បានអនុវត្តការងារចាំបាច់ផ្សេងៗ មួយចំនួនទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ៤.១.២ ការងារកិច្ចសហប្រតិបត្តិការ

ក្នុងកិច្ចសហប្រតិបត្តិការថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសតំណាងឱ្យអាជ្ញាធរទន្លេសាប បានធ្វើការទំនាក់ទំនង និងទទួលជួបពិភាក្សាការងារសហប្រតិបត្តិការជាមួយបណ្ដាក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិនានា រួមមាន (World Bank, ADB, USAID, JICA, Mekong-Lancang Cooperation...) ក្នុងការចូលរួមសមាហរណកម្មការយល់ដឹង និងចែករំលែកនូវព័ត៌មាន ទិន្នន័យ បង្ហាញពីលទ្ធផលសកម្មភាពសិក្សាស្រាវជ្រាវរបស់អាជ្ញាធរទន្លេសាប ក្នុងកិច្ចប្រជុំ ប្រឹក្សាយោបល់ ជាពិសេសជាមួយដៃគូគម្រោងពាក់ព័ន្ធ ដែលមានសកម្មភាពដូចជា ៖

#### ក. ការងារចុះទស្សនកិច្ចសិក្សា

ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប បានអញ្ជើញដឹកនាំគណៈប្រតិភូ សមាជិកអាជ្ញាធរទន្លេសាប ដែលជាតំណាងក្រសួងស្ថាប័ន និងអាជ្ញាធរខេត្តពាក់ព័ន្ធ ធ្វើដំណើរទស្សនកិច្ចសិក្សាស្វែងយល់ពីសក្ដានុពលតំបន់បឹងទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រ ខេត្តសៀមរាប។





ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប រួមជាមួយ ឯកឧត្តម Li Guoying រដ្ឋមន្ត្រីក្រសួងធនធានទឹក នៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំគណៈប្រតិភូចុះទស្សនកិច្ចស្វែងយល់អំពីតំបន់បឹងទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រ ខេត្តសៀមរាប។





#### ខ. កិច្ចប្រជុំពិគ្រោះយោបល់ក្នុងប្រទេស

១. ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ស្ដីពីការកសាងកិច្ចសហការរួមគ្នាសម្រាប់សន្តិសុខទឹក និងភាពធន់នៅបឹងទន្លេសាប ដោយមានកិច្ចសហការជាមួយធនាគារពិភពលោក(WB), ក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្ម (DFAT) និង Australian Water Partnership (AWP) ក្នុងការអនុវត្តកម្មវិធីវាយតម្លៃសន្តិសុខទឹក និងភាពធន់នៃបឹងទន្លេសាប សម្រាប់ឆ្នាំ ២០២៤-២០២៦។

២. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដឹកនាំមន្ត្រីបច្ចេកទេស ជួបប្រជុំជាមួយលោក Sebastian Sabogal ប្រធានអភិវឌ្ឍន៍អាជីវកម្មតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងលោកស្រី Ally Lynch អ្នកជំនាញបម្រែបម្រួលអាកាសធាតុតំណាងក្រុមហ៊ុន





ប្រឹក្សា និងស្រាវជ្រាវ Abt Global ពិភាក្សាអំពីឱកាសសហការ និងពិភាក្សាដើម្បីស្វែងយល់អំពីបញ្ហា និងឱកាសក្នុងការគ្រប់គ្រងទឹកក្នុងអាងទន្លេសាប ក្រោមកម្មវិធីភាពធន់នឹងអាកាសធាតុកម្ពុជា (CCRP) របស់រដ្ឋាភិបាលអូស្ត្រាលី។

៣. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីពិនិត្យ និងពិភាក្សាអំពីឯកសារទស្សនទានស្តីពី "គំនិតផ្តួចផ្តើមដើម្បីចីរភាពបរិស្ថានទន្លេសាប "។

៤. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប ចូលរួមកិច្ចប្រជុំពិភាក្សាលើការរៀបចំ Concept Note ក្រោមចំណងជើងថា ភាពសម្បូរត្រីនៅកម្ពុជា ដើម្បីស្នើ Fund ពី GCF ដែលបានរៀបចំឡើងដោយអង្គការស្បៀងអាហារពិភពលោកកម្ពុជា (FAO) នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៥. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដឹកនាំមន្ត្រីបច្ចេកទេសជួបប្រជុំពិភាក្សាជាមួយ លោកបណ្ឌិត ណា កាម៉ូរ តាកាស៊ី ( Dr.NAKAMURA Takashi ) សាស្ត្រាចារ្យ និងកញ្ញា ដេត មួយគាង និស្សិតបរិញ្ញាបត្រជាន់ខ្ពស់នៃសកលវិទ្យាល័យ យ៉ាម៉ាណាស៊ី ( University of Yamanashi ) ប្រទេសជប៉ុន តាមប្រព័ន្ធ Virtual Microsoft Team Meeting Room។

៦. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដឹកនាំមន្ត្រីបច្ចេកទេសជួបប្រជុំពិភាក្សាជាមួយក្រុមជំនាញការដៃគូអភិវឌ្ឍន៍ លោកបណ្ឌិត Morgan MARTEAU ប្រធានក្រុមប្រឹក្សាជួយកិច្ចការធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងលោកបណ្ឌិត Phillip GOURBESVILLE ក្រុមការងារស្ថាប័នជំនួយនៃវិទ្យាស្ថានធនធានទឹក និងវារីសាស្ត្រ ( Institute of Water Resources and Hydropower ) ប្រទេសចិន រួមជាមួយ លោក ថ្លាង ភក្ត្រា ទទួលបន្ទុកគម្រោង ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ ( AFD ) និងសហការី។





៧. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប និងមន្ត្រីបច្ចេកទេស បានដឹកនាំកិច្ចប្រជុំស្តីពីការពង្រឹងប្រសិទ្ធភាពយន្តការការងារតំបន់អភិរក្សជីវចម្រុះបឹងពារាំង ជាមួយអន្តរក្រសួង និងស្ថាប័នពាក់ព័ន្ធនៅសាលាខេត្តសៀមរាប។

៨. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដឹកនាំមន្ត្រីបច្ចេកទេស ជួបប្រជុំពិភាក្សាជាមួយ លោកបណ្ឌិត Robert Rout និងលោក សាយ ណាល់ អ្នកជំនាញមកពីធនាគារអភិវឌ្ឍន៍អាស៊ី ( ADB ) នៅសាលប្រជុំអាជ្ញាធរទន្លេសាប។

៩. មន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប បានចូលរួមកិច្ចប្រជុំពិភាក្សា ជាមួយក្រុមការងារ និងជំនាញការទីប្រឹក្សារបស់កម្មវិធី ស្តីពីការពិនិត្យលើផែនការការងារ សម្រាប់គាំទ្រដល់ក្រសួងធនធានទឹក និងឧតុនិយម នៃកម្មវិធីអភិបាលកិច្ចធនធានទឹកធន់នឹងបម្រែបម្រួលអាកាសធាតុនៅកម្ពុជា រយៈពេល ៥ឆ្នាំ និងផែនការសកម្មភាពការងារអនុវត្តកម្មវិធី។

១០. ថ្នាក់ដឹកនាំអាជាជ្ញាធរទន្លេសាប បានទទួលជួបពិភាក្សាការងារជាមួយប្រតិភូតំណាង Global Green Growth Institute លើគម្រោងគំនិតផ្តួចផ្តើមដើម្បីនិរន្តរភាពបរិស្ថានតំបន់ទន្លេសាប ដោយផ្តោតសំខាន់ទៅលើការបន្សាំទៅនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ។





១១. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដឹកនាំមន្ត្រីបច្ចេកទេស ជួបពិភាក្សាការងារជាមួយគណៈប្រតិភូមេគង្គ-ឡានឆាង ដឹកនាំដោយឯកឧត្តម Dr. **Zhou Zhiwei** អគ្គលេខាធិការមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹកឡានឆាង-មេគង្គ (Lancang-Mekong Water Resources Cooperation Center-LMC)។

១២. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប និងមន្ត្រីបច្ចេកទេស អញ្ជើញទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូវិទ្យាស្ថានស្រាវជ្រាវជលសាស្ត្រ ណានជីង នៃក្រសួងធនធានទឹកសាធារណរដ្ឋប្រជាមានិតចិន។

១៣. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដឹកនាំមន្ត្រីបច្ចេកទេសចូលរួមចុះពិនិត្យទីតាំងជាក់ស្តែង ដែលតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ លើកកម្ពស់តំបន់សហគមន៍ទេសចរណ៍ធម្មជាតិក្នុងតំបន់បឹងទន្លេសាប ដែលរៀបចំដោយក្រសួងទេសចរណ៍ និងគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

១៤. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានចូលរួមកិច្ចប្រជុំប្រឹក្សាយោបល់ ស្តីពីការផ្តួចផ្តើមដើម្បីចីរភាពបរិស្ថានទន្លេសាប ដែលសហការរៀបចំឡើងដោយ Global Green Growth Institute (GGGI) ជាមួយក្រសួងបរិស្ថាន នៅសណ្ឋាគារ Sangri La ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ជាច្រើន។

១៥. មន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការគ្រប់គ្រងតំបន់បឹងទន្លេសាប និងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ នៅខេត្តសៀមរាប។

១៦. មន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប ចូលរួមកិច្ចប្រជុំប្រឹក្សាយោបល់ ជាមួយក្រុមការងារតំណាងអង្គការ UNESCO លើគម្រោងនៃការគ្រប់គ្រងទឹកឆ្លងដែន (Transboundary Water Projects)។

១៧. មន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប បានអញ្ជើញចូលរួមជាវាគ្មិន ក្នុងកិច្ចពិភាក្សាអំពីការគ្រប់គ្រងធនធានទឹក និងការត្រួតពិនិត្យការបំពុល ក្នុងនាមជាអ្នកបច្ចេកទេសសិក្សាស្រាវជ្រាវវ័យក្មេងរបស់អាជ្ញាធរទន្លេសាប ក្នុងសន្និសីទថ្នាក់ជាតិ ស្តីពីបបនីយជីវមណ្ឌលបឹងទន្លេសាប ដែលរៀបចំដោយក្រសួងបរិស្ថាន។





១៩. មន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីកម្មវិធីអភិបាលកិច្ចធនធានទឹកធន់នឹងការប្រែប្រួលអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ Sun & Moon រាជធានីភ្នំពេញ។

២០. ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប បានជួបប្រជុំពិភាក្សាការងារជាមួយក្រុមអ្នកជំនាញចិន នៃវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រទន្លេឆាងជាំង (Changjiang River Scientific Research Institute) ដឹកនាំដោយ Mr.Zhou Yinjun, Deputy Director of River Research Department (RRD), CRSRI នៅលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប។

២១. មន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប បានចូលរួមកិច្ចប្រជុំពិភាក្សាបូកសរុបលទ្ធផល នៃដំណើរទស្សនកិច្ចសិក្សាប្រមូលព័ត៌មានជាមួយក្រុមអ្នកជំនាញការចិន (BOH)។





២២. ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប ចូលរួមសិក្ខាសាលាថ្នាក់ជាតិលើប្រធានបទ ស្តីពីការវាយតម្លៃតម្រូវការក្នុងការត្រៀមខ្លួនសម្រាប់មូលនិធិអាកាសធាតុបៃតងក្នុងប្រទេសកម្ពុជា (The Green Climate Fund (GCF)។

២៣. ក្រុមការងារមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប ទទួលបន្ទុកអនុវត្តគម្រោងក្រោមកិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន បានទទួលជួបជាមួយក្រុមអ្នកជំនាញការចិន មកពីវិទ្យាស្ថានស្រាវជ្រាវជលសាស្ត្រណានជីង (NHRI) ដើម្បីពិភាក្សាការងារលើវិស័យដូចជា ការបង្ការគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ការគ្រប់គ្រងទឹក និងអភិបាលកិច្ចបរិស្ថានទឹក ក្រោមបរិបទនៃការប្រែប្រួលអាកាសធាតុ ព្រមទាំងធ្វើទស្សនកិច្ចសិក្សាប្រមូលព័ត៌មានបែបវិទ្យាសាស្ត្រនៅតាមដងទន្លេសាប រហូតដល់តំបន់បឹងទន្លេសាប។

២៤. ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការតាមដានវាយតម្លៃប្រព័ន្ធវិកាសមិទ្ធកម្មថ្នាក់ជាតិ ដែលរៀបចំឡើងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៥. ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសចូលរួមសិក្ខាសាលាផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តសៀវភៅគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMM) របស់ក្រសួងធនធានទឹក និងឧតុនិយម។









## គ. កិច្ចប្រជុំពិគ្រោះយោបល់ក្រៅប្រទេស

ឯកឧត្តម ហៃល តូនី អនុប្រធានក្តាប់រួម តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប រួមជាមួយលោកបណ្ឌិត អ៊ុក សុវណ្ណារ៉ា ជំនួយការផ្ទាល់របស់ឯកឧត្តមអនុប្រធានក្តាប់រួម បានចូលរួមកិច្ចពិភាក្សានៅប្រទេសសិង្ហបុរី ស្តីពីសន្តិសុខទឹក និងភាពធន់ក្នុងវិស័យធនធានទឹក ជាមួយធនាគារពិភពលោក (World Bank) មជ្ឈមណ្ឌលទឹកនៃសិង្ហបុរី (Singapore Water Centers) និងតំណាងប្រទេសមួយចំនួនក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។






មន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប បានចូលរួមកិច្ចប្រជុំថ្នាក់តំបន់លើកទី២១ នៃក្រុមអ្នកជំនាញការ ស្តីពីទិន្នន័យម៉ូដែល និងការព្យាករ ដោយផ្តោតលើម៉ូដែលក្របខ័ណ្ឌគាំទ្រការធ្វើសេចក្តីសម្រេចចិត្ត (DSF) របស់គណៈកម្មការទន្លេមេគង្គនៅទីក្រុងហាណូយ ប្រទេសវៀតណាម។

### ៤.១.៣ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន






តាមរយៈកិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរទន្លេសាប និងគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែនក្នុងឆ្នាំ២០២៥ ឯកឧត្តម លឹម ពុយ អនុប្រធានអាជ្ញាធរទន្លេសាប និងជាប្រធានក្រុមការងារគម្រោងគ្រប់គ្រងធនធានទឹកចម្រុះនៃអាងស្ទឹងសែន បានទទួលលទ្ធផល ដូចខាងក្រោម៖

១- បានដឹកនាំក្រុមការងារទី៣ ផ្នែកបរិស្ថានក្នុងគម្រោងការគ្រប់គ្រងធនធានទឹកចម្រុះនៃអាងស្ទឹងសែន ចុះសិក្សាតាមដានលើធនធានត្រី និងប្រភេទបួងគុងដែលជាចំណីរបស់ធនធានត្រីនៅអាងស្តុកទឹករក្សា ស្រុករវៀង ខេត្តព្រះវិហារ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយកងពលតូចលេខ៧០ និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រះវិហារ ក្នុងគោលបំណងសំខាន់ដូចខាងក្រោម៖

- សិក្សាតាមដានលើប្រភេទត្រី និងការលូតលាស់របស់ប្រភេទត្រី ព្រមទាំងប្រភេទបួងគុងដែលជាចំណីរបស់ធនធានត្រីនៅក្នុងទំនប់រក្សា ក្រោយពេលដែលទំនប់នេះបានដំណើរការអស់រយៈពេល ២ឆ្នាំ
- វាយតម្លៃលើបរិមាណផលចាប់ប្រចាំថ្ងៃរបស់អ្នកនេសាទដោយប្រើប្រាស់ឧបករណ៍ចំនួន ៣ប្រភេទ គឺ មងរាយ លប និងសន្ទូចរនង ព្រមទាំងស្រង់ប្រភេទឧបករណ៍នេសាទដែលអ្នកនេសាទកំពុងប្រើប្រាស់នៅក្នុងតំបន់ទំនប់រក្សា
- សិក្សាចរន្ត និងតម្លៃទីផ្សារត្រីក្នុងតំបន់អាងស្តុករក្សា
- វាយតម្លៃលើចំនួនប្រជានេសាទ ដែលធ្វើអាជីវកម្មលក្ខណៈគ្រួសារនៅអាងស្ទឹងសែន។

២- បានរៀបចំទទួលគណៈប្រតិភូប្រទេសឡាវ ក្នុងបេសកកម្មផ្លាស់ប្តូរបទពិសោធន៍ថ្នាក់តំបន់ រវាងដៃគូក្នុងប្រទេសឡាវ និងកម្ពុជា ស្តីពីការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ក្នុងក្របខ័ណ្ឌនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះនៅកម្ពុជា (គម្រោងសាកល្បងអាងស្ទឹងសែន ២០២៤-២០២៦ វដ្តទី២) ដំណាក់កាលទី២ ក្រោមជំនួយហិរញ្ញប្បទានដោយភ្នាក់ងារទឹករបស់បារាំង Loire-Bretagne និង Rhin-Meuse សហការជាមួយការិយាល័យទឹកអន្តរជាតិបារាំង(OiEau) គោលបំណងរួមនៃកិច្ចប្រជុំការផ្លាស់ប្តូរបទពិសោធន៍ថ្នាក់តំបន់នេះ គឺដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងសិក្សាស្វែងយល់ពីការគ្រប់គ្រងធនធានទឹកចម្រុះ គោលនយោបាយទឹក និងអភិបាលកិច្ចទឹករវាងក្រសួងធនធានទឹក និងឧតុនិយមនៃប្រទេសកម្ពុជា និងក្រសួងធនធានធម្មជាតិ និងបរិស្ថាននៃប្រទេសឡាវ និងចុះទស្សនកិច្ចសិក្សាប្រពន្ធ័ជារាសាស្រ្តទំនប់អូរកំបោរ-អូរសេករាជ និងអាងទឹកទំនប់រក្សា ដែរស្ថិតឃុំរក្សា ខេត្តព្រះវិហារ។

### ៤.១.៤ គម្រោងការតាមដានផលចាប់នៅខេត្តជុំវិញបឹងទន្លេសាប

គម្រោងការតាមដានភាពសម្បូរបែប និងនានាភាពនៃប្រភេទត្រី តាមបណ្តាខេត្តជុំវិញបឹងទន្លេសាប ត្រូវបានអនុវត្តដោយអាជ្ញាធរទន្លេសាប (TA) ចាប់តាំងពី ឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ន ដោយមានការគាំទ្រពី គណៈកម្មការទន្លេមេគង្គ (MRC) និងសម្របសម្រួលដោយគណៈកម្មការជាតិទន្លេមេគង្គកម្ពុជា។ ការសិក្សានេះ គឺជាផ្នែកបន្តពីគម្រោងស្រាវជ្រាវពីមុនៗក្នុងតំបន់មេគង្គ ដែលបានចាប់ផ្តើមតាំងពីឆ្នាំ២០០៦។

❖ **គោលបំណងសំខាន់ៗ៖**

១. ប្រមូលទិន្នន័យផលចាប់របស់អ្នកនេសាទ តាមដានភាពសម្បូរបែប និងនានាភាពរបស់ត្រី
២. ធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យជាតិ ស្តីពីភាពសម្បូរបែប និងនានាភាពនៃប្រភេទត្រី
៣. រៀបចំរបាយការណ៍ដែលពន្យល់ពីស្ថានភាព និងនិន្នាការនៃធនធានជលផលនៅតំបន់បឹងទន្លេសាប។

❖ **លទ្ធផលអនុវត្តគម្រោងក្នុងឆ្នាំ២០២៥ ៖**

- ការតាមដានភាពសម្បូរបែប និងនានាភាពនៃប្រភេទត្រីធ្វើឡើងនៅ ៣៨ទីតាំង ក្នុងប្រទេសសមាជិក MRC ( កម្ពុជា ឡាវ ថៃ វៀតណាម ) ដោយរាប់បញ្ចូលទាំងទន្លេមេគង្គ ដៃទន្លេធំៗ វាលទំនាបលិចទឹក មាត់សមុទ្រ និងប្រឡាយ
- រៀបចំសិក្ខាសាលាជាមួយអ្នកនេសាទ ប្រមូលទិន្នន័យកត់ត្រាប្រចាំថ្ងៃ និងធ្វើទស្សនកិច្ចត្រីមាស
- ពិនិត្យ បញ្ចូល ដំណើរការ និងវិភាគទិន្នន័យ រួមទាំងធ្វើបច្ចុប្បន្នភាពរូបថតត្រី និងឈ្មោះប្រភេទត្រី
- បណ្តុះបណ្តាលអ្នកនេសាទលើការតាមដានប្រើមងរាយ ដែលមានក្រឡាច្រើនទំហំ និងចុះដល់ទីតាំង ព្រមទាំងពិនិត្យមើលទិន្នន័យជាមួយអ្នកនេសាទ ដើម្បីត្រួតពិនិត្យ វាយតម្លៃភាពជាក់ស្តែង និងប្រមូលសៀវភៅកត់ត្រា
- បញ្ជូនរបាយការណ៍ចុងក្រោយ ដែលបានធ្វើបច្ចុប្បន្នភាព សម្អាត និងវិភាគទិន្នន័យរួចរាល់ទៅផ្នែកបរិស្ថាននៃគណៈកម្មការទន្លេមេគង្គ តាមរយៈគណៈកម្មការជាតិទន្លេមេគង្គកម្ពុជា ព្រមទាំងសង្ខេបសម្រាប់ធ្វើការបោះពុម្ពផ្សាយនៅក្នុង MRCS-ED: Catch and Culture-Environment
- ថ្នាក់ដឹកនាំ និងមន្រ្តីអនុវត្តគម្រោង បានចូលរួមវគ្គបណ្តុះបណ្តាល លើផែនការការងារគ្រប់គ្រងគម្រោង និងផ្នែកបច្ចេកទេស នៅក្រៅប្រទេស ( ឡាវ, ថៃ, វៀតណាម )
- បានដឹកនាំមន្ត្រី MRC និង CNC-Mekong ធ្វើទស្សនកិច្ចនៅតាមទីតាំងសិក្សាចំនួន ៥ខេត្ត ជុំវិញបឹងទន្លេសាប និងធ្វើទស្សនកិច្ចនៅប្រទេសឡាវ។






## ៤.១.៥ គម្រោងសហប្រតិបត្តិការជាមួយធនាគារពិភពលោក ( WB ) ស្តីពីការវាយតម្លៃសន្តិសុខទឹកក្នុងអាងទន្លេសាប

ក្រោមកិច្ចសហប្រតិបត្តិការជាមួយធនាគារពិភពលោក DFAT និង AWP ក្នុងការអនុវត្តកម្មវិធីសន្តិសុខទឹក និងភាពធន់របស់បឹងទន្លេសាប អាជ្ញាធរទន្លេសាប បានសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ក្នុងការរៀបចំកិច្ចប្រជុំ សិក្ខាសាលាពិគ្រោះយោបល់ និងចុះប្រមូលរាល់ព័ត៌មាន ទិន្នន័យ ដោយទទួលបាននូវធាតុចូលបន្ថែមទៀត ដើម្បីឈានទៅរៀបចំបានជារបាយការណ៍បឋម ស្តីពីស្ថានភាពអាងទន្លេសាប។ គំនិតផ្តួចផ្តើមនេះ មានគោលបំណងគាំទ្រដល់










អាជ្ញាធរទន្លេសាប ក្នុងការអភិវឌ្ឍការយល់ដឹងទូលំទូលាយដោយផ្អែកលើវិទ្យាសាស្ត្រទឹក អំពីបញ្ហាប្រឈមនានានៃសន្តិសុខទឹក និងកំណត់ផ្លូវប្រកបដោយនិរន្តរភាពសម្រាប់ភាពធន់ដែលសម្របខ្លួននៅក្នុងអាងទន្លេសាប និងឈានទៅរៀបចំបានជារបាយការណ៍ ស្តីពីស្ថានភាពអាងទន្លេសាប។

## ៤.១.៦ ការងារបច្ចេកទេសសិក្សាស្រាវជ្រាវ

ក្នុងស្មារតីយកចិត្តទុកដាក់អនុវត្តបេសកកម្មការងារដូចកំណត់ក្នុងច្បាប់បទដ្ឋានគតិយុត្ត និងផែនការយុទ្ធសាស្ត្រឱ្យទទួលបានជោគជ័យតាមគោលដៅ និងទិសដៅរំពឹងទុក អាជ្ញាធរទន្លេសាប បានដាក់ចេញនូវផែនការសកម្មភាពអនុវត្តប្រចាំឆ្នាំ ដោយមានការប្រមូលចងក្រង និងវិភាគព័ត៌មាន ទិន្នន័យ ដែលបានពីការចុះសិក្សាស្រាវជ្រាវ និងស្វែងយល់ជាក់ស្តែងជាច្រើន នៅក្នុងតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ដើម្បីពង្រឹងដល់ការយល់ដឹង តាមរយៈការផ្សព្វផ្សាយ និងចែករំលែកដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត អ្នកសិក្សាស្រាវជ្រាវ និងអ្នករៀបចំគោលនយោបាយ កម្មវិធី/គម្រោង ផែនការយុទ្ធសាស្ត្រ។ល។ អំពីការគ្រប់គ្រងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។

សកម្មភាពចុះសិក្សាស្រាវជ្រាវនេះ អាជ្ញាធរទន្លេសាប បានយកចិត្តទុកដាក់ក្នុងការវិភាគចងក្រងនូវរាល់ព័ត៌មានទិន្នន័យពាក់ព័ន្ធ រួមមាន៖

**(១). សៀវភៅកម្រងរូបភាពត្រីទន្លេមេគង្គ និងតំបន់ពាក់ព័ន្ធបឹងទន្លេសាប**

**(២). សៀវភៅការសិក្សាពីប្រភេទព្រៃលិចទឹកតំបន់ទន្លេសាប**

**(៣). សៀវភៅការសិក្សាពីប្រភេទសត្វស្លាបនៅតំបន់ទន្លេសាប**

**(៤). សៀវភៅការសិក្សាតាមដានអាជីវកម្មឡូតិ៍ជាយរដូវនេសាទឆ្នាំ ២០២៤-២០២៥**






លទ្ធផលការសិក្សាស្រាវជ្រាវឆ្នាំ២០២៥ និងការធ្វើបច្ចុប្បន្នភាព ព័ត៌មានទិន្នន័យដែលមានស្រាប់ បានមកពីប្រភពពាក់ព័ន្ធនានា បានឆ្លុះបញ្ចាំងឱ្យឃើញពីរបកគំហើញក្នុងការប្រែប្រួលបរិយាកាសស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន និងដំណើរការគ្រប់គ្រងពីអ្នកពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោលមកលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ រួមមាន៖ ធនធានជលផលរបបជលសាស្ត្រ ធនធានទឹក ជីវសាស្ត្រចម្រុះ ការទ្រទ្រង់ជីវភាពរស់នៅ ការប្រើប្រាស់ដីធ្លី ការធ្វើអាជីវកម្ម កសិកម្ម ព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប។ល។ ជារួមតាមការសិក្សា និងវិភាគបង្ហាញឱ្យឃើញពីភាពថយចុះ និងការគំរាមកំហែងឥតឈប់ឈរគួរឱ្យព្រួយបារម្ភមកលើធនធានដ៏កម្រក្នុងតំបន់បឹងទន្លេសាបនាពេលបច្ចុប្បន្ន និងពេលអនាគត ចំពោះសកម្មភាព

អនាធិបតេយ្យ ដោយការធ្វើអាជីវកម្មហួសកម្រិត ក្នុងការទាញយកអត្ថប្រយោជន៍ធនធានធម្មជាតិពីបឹងទន្លេសាប និងការទទួលរងនូវផលប៉ះពាល់ពីការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធតំបន់មេគង្គលើ តំបន់បឹងទន្លេសាប និងលើផ្ទៃរងទឹកភ្លៀងតំបន់បឹងទន្លេសាប។



## ៥.១.៧ ការងារគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន

### ក. ការងារគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន



ព័ត៌មានទិន្នន័យ គឺជាធាតុចូលមួយដ៏សំខាន់ សម្រាប់បម្រើឱ្យស្ថាប័ន/អង្គភាព ក្នុងការធ្វើការវិភាគ ដើម្បីរៀបចំឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធី/គម្រោងនានា ជាពិសេសសម្រាប់បម្រើដល់អ្នកសិក្សាស្រាវជ្រាវ និងអ្នកធ្វើសេចក្តីសម្រេចចិត្តយកទៅប្រើប្រាស់ជាមូលដ្ឋានក្នុងតម្រូវការផ្សេងៗ។ ការប្រមូលចងក្រង និងគ្រប់គ្រងព័ត៌មានទិន្នន័យពាក់ព័ន្ធតំបន់ទន្លេសាប ជាការងារអាទិភាពក្នុងចំណោម ការងារអាទិភាពដទៃទៀត ដែលបានកំណត់នៅក្នុងតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរទន្លេសាប តាមរយៈលទ្ធផលបានមកពីសកម្មភាពចុះសិក្សាស្រាវជ្រាវ និងសិក្សាស្វែងយល់ របស់ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប។ ព័ត៌មាន ទិន្នន័យពាក់ព័ន្ធតំបន់ទន្លេសាប ត្រូវបានសិក្សាស្រាវជ្រាវ និងប្រមូលផ្តុំទៅតាមគម្រោងសកម្មភាពនីមួយៗ ដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប ដើម្បីប្រមូលចងក្រង វិភាគ និងប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធ សំដៅទៅរកការរៀបចំរបាយការណ៍បច្ចេកទេសសិក្សាស្រាវជ្រាវ កសាងផែនការយុទ្ធសាស្ត្រ កម្មវិធី/គម្រោង និងធ្វើការផ្សព្វផ្សាយ ចែករំលែកដល់អ្នកពាក់ព័ន្ធ ក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយនិរន្តរភាព។




អាជ្ញាធរទន្លេសាប បច្ចុប្បន្នបាននិងកំពុងតែគិតគូររៀបចំបរិវត្តកម្មប្រព័ន្ធគ្រប់គ្រងព័ត៌មានទិន្នន័យ (Data Server Management) ទាំងផ្នែករដ្ឋបាល បុគ្គលិក គណនេយ្យ និងកិច្ចការស្រាវជ្រាវ ឱ្យបានត្រឹមត្រូវស្របតាមបរិបទបច្ចេកវិទ្យាឌីជីថល ដែលនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ដើរតួនាទីជាឆ្អឹងខ្នង សម្រាប់ស្ថាប័នក្នុងការសម្របសម្រួលលើការប្រមូលផ្តុំ គ្រប់គ្រង និងចែករំលែកឱ្យមានប្រសិទ្ធភាព។

## ខ. ការងារគ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មាន

### ១. ការងារផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល



ការគ្រប់គ្រង ផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន ត្រូវបានកំណត់ជាសកម្មភាពអាទិភាពក្នុងការជំរុញសកម្មភាពសិក្សាស្រាវជ្រាវឱ្យកាន់តែមានលក្ខណៈវិទ្យាសាស្ត្រ និងត្រូវបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទទួលខុសត្រូវរបស់អាជ្ញាធរទន្លេសាប ដែលជាស្ថាប័នសិក្សាស្រាវជ្រាវ ប្រមូលចងក្រងរាល់ព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងតំបន់ទន្លេសាប។ ការផ្សព្វផ្សាយ និងចែករំលែកនេះ គឺសកម្មភាពបញ្ជ្រាបការយល់ដឹង ដល់អ្នកពាក់ព័ន្ធ និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូ ទាំងកម្រិតថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកអនុវត្តដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប។

បច្ចុប្បន្ន នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប បាននិងកំពុងតែដំណើរការការផ្សព្វផ្សាយ និងចែករំលែក តាមរយៈនៃការបោះពុម្ពផ្សព្វផ្សាយឯកសារពាក់ព័ន្ធ ផលិតវីដេអូឯកសារ បង្ហាញពីសមិទ្ធផលនានា នៃសកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប និងបានធ្វើការផ្សព្វផ្សាយ ចែករំលែកទៅដល់ក្រសួង-ស្ថាប័នដៃគូពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាននៅជុំវិញតំបន់បឹងទន្លេសាប និងនៅលើប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គម (Website, Facebook, Telegram Channel, Youtube Channel,Twitter)។ អាជ្ញាធរទន្លេសាប ក៏បាននិងកំពុងតែគិតគូររៀបចំបរិវត្តកម្មផងដែរទៅលើការគ្រប់គ្រងប្រសិទ្ធភាពនៃប្រព័ន្ធបណ្តាញផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន ចំណេះដឹងឱ្យបានដល់អ្នកប្រើប្រាស់ ឬក្រុមគោលដៅក្នុងការទទួលបាននូវភាពងាយស្រួល ជាពិសេស បាននិងកំពុងតែរៀបចំកសាងនូវផែនការប្រាស្រ័យទាក់ទងដើម្បីពង្រីកសកម្មភាពសេវាកម្មបច្ចេកវិទ្យាព័ត៌មាន។







គំរូបណ្ណសម្គាល់ខ្លួនមន្ត្រីរាជការអាជ្ញាធរទន្លេសាប





### ២. ការងារផ្សព្វផ្សាយដល់អាជ្ញាធរមូលដ្ឋាន

អាជ្ញាធរទន្លេសាប បានបន្តដឹកនាំក្រុមការងារទទួលបន្ទុកផ្សព្វផ្សាយ ទាក់ទងច្បាប់ បទដ្ឋានគតិយុត្ត ពាក់ព័ន្ធការការពារព្រៃលិច និងដែនព្រៃលិចទឹក និងការចូលរួមលើកកម្ពស់យេនឌ័រក្នុងការអភិរក្សធនធានជលផល និងបរិស្ថានទៅដល់ស្ថាប័នជំនាញពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ភូមិ/ឃុំ/ស្រុក និងប្រជាពលរដ្ឋស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប។



## ៤.២ ការងារចំពោះមុខ

### ៤.២.១ ការងារចុះផ្ទៀងផ្ទាត់និយាមការ និងបោះបង្គោលព្រំការពារដីកាត់ឆ្ងៀល

### ក. ការងារផ្ទៀងផ្ទាត់ទិន្នន័យ និងកំណត់និយាមការ

អាជ្ញាធរទន្លេសាប បានបន្តបោះបង្គោលជំហាន២ បង្គោលព្រំការពារដីតំបន់កាត់ឆ្ងៀល (តំបន់១ និងតំបន់២ ស្ថិតក្នុងតំបន់៣) នៅខេត្តទាំង៦ ជុំវិញបឹងទន្លេសាប ដោយក្នុងឆ្នាំ២០២៥ នេះ អាជ្ញាធរទន្លេសាបអនុវត្តការងារបោះបង្គោលព្រំនៅខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ។



## ខ. ការងារសាងសង់បង្គោលកាត់ផ្ទៀល









## គ. សកម្មភាពចុះពិនិត្យវាយតម្លៃ និងប្រគល់ទទួល ការងារបោះបង្គោលព្រំកាត់ផ្ទៀល








## ឃ. ការងារអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក

អាជ្ញាធរទន្លេសាប បានបន្តដឹកនាំក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក តាមមុខព្រួញផ្លូវជាតិលេខ៥ និងផ្លូវជាតិលេខ៦ ដើម្បីតាមដានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់និយាមកាបង្គោលព្រំការពារដែនព្រៃលិចទឹក និងព្រៃលិចទឹក តាមស្មារតីអនុក្រឹត្យលេខ១៩៧ អនក្រ.បក ក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ដោយមានកិច្ចចូលរួមសហការពីស្ថាប័ន មន្ទីរជំនាញជុំវិញខេត្ត អាជ្ញាធរដែនដីពាក់ព័ន្ធតំបន់បឹងទន្លេសាប លើកិច្ចការការពារធនធានធម្មជាតិ ពិសេសព្រៃលិចទឹក និងដែនព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាពខ្ពស់។










## ង. ការងារចុះពិនិត្យស្ថានភាពទឹកជំនន់តាមបណ្តាស្ទឹងសំខាន់ៗ ជុំវិញបឹងទន្លេសាប

ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប បានដឹកនាំក្រុមការងារ អញ្ជើញចុះពិនិត្យស្ថានភាពជាក់ស្តែងជំនន់ទឹកភ្លៀងក្នុងភូមិសាស្ត្រខេត្តកំពង់ធំ និងខេត្តសៀមរាប។

ដោយទទួលបានការណែនាំចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរទន្លេសាប ថ្នាក់ដឹកនាំ និងក្រុមការងារទទួលបន្ទុកមុខព្រួញផ្លូវជាតិលេខ៥ និងផ្លូវជាតិលេខ៦ បានដឹកនាំក្រុមការងារ មន្ត្រីបច្ចេកទេស សហការជាមួយនឹងមន្ទីធនធានទឹក និងឧតុនិយម ខេត្តទាំង៦ ចុះពិនិត្យស្ថានភាពទឹកជំនន់តាមបណ្តាស្ទឹងសំខាន់ៗជុំវិញបឹងទន្លេសាប។







*សកម្មភាពចុះពិនិត្យស្ថានភាពទឹកជំនន់តាមបណ្ដាស្ទឹងសំខាន់ៗ ជុំវិញបឹងទន្លេសាប (មុខព្រួញផ្លូវជាតិលេខ៥)*



*សកម្មភាពចុះពិនិត្យស្ថានភាពទឹកជំនន់តាមបណ្ដាស្ទឹងសំខាន់ៗ ជុំវិញបឹងទន្លេសាប (មុខព្រួញផ្លូវជាតិលេខ៦)*

## ខ. ការងារចុះសម្របសម្រួលពាក់ព័ន្ធ និងបញ្ហាក្នុងបឹងទន្លេសាប

ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប រួមជាមួយតំណាងក្រសួងធនធានទឹក និងឧតុនិយម បានដឹកនាំមន្ត្រីបច្ចេកទេស ដោយមានកិច្ចសហការចូលរួមពីរដ្ឋបាលខេត្តកំពង់ឆ្នាំង រួមជាមួយមន្ទីរជំនាញ អាជ្ញាធរក្រុង-សង្កាត់ និងកងកម្លាំងសមត្ថកិច្ច រដ្ឋបាលមូលដ្ឋាន សង្កាត់ខ្សាម និងសង្កាត់ផ្សារឆ្នាំង ចុះពិនិត្យករណីចាក់ដីចូលក្នុងទន្លេសាប ស្ថិតក្នុងភូមិសាស្រ្តភូមិទី១ សង្កាត់ខ្សាម និងភូមិចុងកោះ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។



ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដឹកនាំមន្ត្រីជំនាញបច្ចេកទេស ចុះពិនិត្យការជីកស្តារបឹងអភិរក្សហាលប្រាបស់សហគមន៍នេសាទល្វា នៅក្នុងតំបន់៣ ស្ថិតក្នុងភូមិសាស្រ្តឃុំល្វា ស្រុកពួក ខេត្តសៀមរាប។



ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាលើសំណើសុំអន្តរាគមន៍ប្រើប្រាស់អាស្រ័យផល និងអភិវឌ្ឍន៍លើផ្ទៃដីទំហំ ៧៧,០៣ហិកតា ស្ថិតក្នុងភូមិជ្រាវ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប នៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់។






ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានចូលរួមប្រជុំអន្តរក្រសួង ស្តីពីការពិនិត្យ និងពិភាក្សាលើសំណើសុំចុះបញ្ជីតំបន់ការពារ និងអភិវឌ្ឍន៍ប្រភពទឹកបឹងទន្លេសាបសម្រាប់ផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងសៀមរាប និងតំបន់ទីប្រជុំជនជុំវិញ។






ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការស្នើសុំជួសជុល សាងសង់ និងស្តារប្រឡាយ ទំនប់ អាងទឹក ស្រះ ត្រពាំង នៅតំបន់២ នៃតំបន់បឹងទន្លេសាប ក្នុងខេត្តសៀមរាប។






ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានសហការជាមួយរដ្ឋបាលខេត្តសៀមរាប ដឹកនាំក្រុមការងារអន្តរក្រសួង និងមន្ទីរពាក់ព័ន្ធ ចុះពិនិត្យស្ថានភាពអនាធិបតេយ្យក្នុងតំបន់២ និងតំបន់៣ ដែលស្ថិតនៅតំបន់អភិរក្សបឹងពារាំង និងតំបន់ជុំវិញរោងចក្រប្រព្រឹត្តកម្មទឹកស្អាតជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។






ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដឹកនាំប្រតិភូអន្តរក្រសួង ជួបប្រជុំពិភាក្សាបច្ចេកទេសលើរបាយការណ៍បច្ចុប្បន្នភាព ស្តីពីការកំណត់តំបន់ការពារ និងអភិវឌ្ឍន៍ប្រភពទឹកបឹងទន្លេសាប សម្រាប់ផ្គត់ផ្គង់ទឹកស្អាត ក្នុងក្រុងសៀមរាប និងតំបន់ជុំវិញ ខេត្តសៀមរាប។






ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដឹកនាំក្រុមការងារបច្ចេកទេសអន្តរក្រសួង និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តសៀមរាប ចុះពិនិត្យស្ថានភាពទីតាំងជាក់ស្តែង ពីដំណើរការជីកកាយស្តាបាតអាងទឹកយកអាចម៍ដី ក្នុងតំបន់២ ស្ថិតក្នុងភូមិសាស្រ្ត សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានទំហំ ៣០៧៥០០ ម៉ែត្រការ៉េ ជាប្រភេទអាជីវកម្មជីកអាចម៍ដី។






ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប ដឹកនាំមន្ត្រីជំនាញបច្ចេកទេស ចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ករណីស្នើសុំគោលការណ៍ស្តាប្រឡាយទឹក ស្ថិតក្នុងភូមិសាស្រ្តឃុំកំពង់ព្រះគគី ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។






## ៤.២.២ ការងារពិនិត្យផ្ទៀងផ្ទាត់ធ្វើបច្ចុប្បន្នភាព និងចងក្រងទិន្នន័យដីធ្លី

### ក. ការងារចុះសហការជាមួយក្រសួងស្ថាប័ន អាជ្ញាធរដែនដី និងមន្ទីរពាក់ព័ន្ធ

ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប បានចូលរួមកិច្ចប្រជុំជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរដែនដីនៃខេត្តទាំង៦ ជុំវិញបឹងទន្លេសាប ក្នុងការចុះពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យដីធ្លី តាមបណ្តាឃុំ ស្រុក ពាក់ព័ន្ធនឹងតំបន់ទន្លេសាប






### ខ. ការងារចុះធ្វើបច្ចុប្បន្នភាពប្រជាសាស្រ្ត សេដ្ឋកិច្ចសង្គម តំបន់បឹងទន្លេសាប

ដើម្បីទទួលបានជាមូលដ្ឋានទិន្នន័យ ព័ត៌មានឱ្យកាន់តែប្រសើរឡើង សំដៅចូលរួមការអនុវត្តស្របជាមួយនឹងទស្សនវិស័យ គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការគិតគូរវែងឆ្ងាយដល់ការប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិតំបន់បឹងទន្លេសាបប្រកបដោយចីរភាព និងនិរន្តរភាព អាជ្ញាធរទន្លេសាប បានសហការជាមួយយក្រសួងធនធានទឹកទឹក និងឧតុនិយម មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាស្រុក ឃុំ និងភូមិគោលដៅ ដើម្បីចុះសិក្សាផ្ទៀតផ្ទាត់ បច្ចុប្បន្នភាព និងស្រង់ទិន្នន័យ ព័ត៌មានអំពីការប្រើប្រាស់ដី-បម្រែបម្រួលដី ប្រភពធនធានទឹក និងធនធានធម្មជាតិពាក់ព័ន្ធស្ថិតក្នុងតំបន់២ និងតំបន់១ ក្នុងភូមិសាស្រ្តខេត្តទាំង៦ ជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ) និងខេត្ត ២ទៀត ដែលជាខេត្តពាក់ព័ន្ធតំបន់ទន្លេសាប (ខេត្តកណ្តាល និងខេត្តកំពង់ចាម)។








## ៤.៣ ការវិភាគមុខងារ និងរចនាសម្ព័ន្ធស្ថាប័ន

- ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានចូលរួមកិច្ចប្រជុំលើការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ស្ថាប័ន ផ្ទៃក្នុងអង្គភាព ជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងមុខងារសាធារណៈ និងក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី។
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប និងបានដាក់ជូនក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សាអ្នកច្បាប់អមក្រសួងធនធានទឹក និងឧតុនិយម ដើម្បីប្រឹក្សាយោបល់ជាមួយអាជ្ញាធរទន្លេសាប។






## ៥. បញ្ហាប្រឈម

- សមត្ថភាព និងការយល់ដឹងរបស់មន្ត្រីលើកិច្ចការបច្ចេកទេស នៅមានកម្រិតក្នុងការអនុវត្តការងារជាក់ស្តែង
- មន្ត្រីបម្រើការងារតាមនាយកដ្ឋាន និងការិយាល័យមួយចំនួនមានចំនួនតិច និងមិនទាន់សមស្របតាមជំនាញ
- មធ្យោបាយ សម្ភារៈសម្រាប់ចុះអនុវត្តការងារ នៅមានការខ្វះខាត
- ធនធានមនុស្ស និងថវិកាមិនទាន់ឆ្លើយតបនឹងទំហំការងារស្នូល និងការងារចំពោះមុខក្នុងការអនុវត្តជាក់ស្តែង
- សម្ភារឧបករណ៍បច្ចេកទេសស្រាវជ្រាវ និងទំនាក់ទំនងព័ត៌មានបែបលក្ខណៈវិទ្យាសាស្ត្រ មិនទាន់ឆ្លើយតប
- កិច្ចសហការ និងចែករំលែកព័ត៌មាន-ទិន្នន័យ ពីបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមិនទាន់បានទូលំទូលាយ
- ទីស្នាក់ការ/អង្គភាព និងមន្ត្រីបង្គោលអាជ្ញាធរទន្លេសាប នៅថ្នាក់ក្រោមជាតិនៃខេត្តទាំង៨ ជុំវិញតំបន់ទន្លេសាប មិនទាន់បានរៀបរយនៅឡើយ។

## ៦. សន្និដ្ឋាន និងទិសដៅការងារបន្ត

ផ្អែកលើសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ និងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២៤-២០២៨ កន្លងមក អាជ្ញាធរទន្លេសាប បានធ្វើការវាយតម្លៃដោយយកចិត្តទុកដាក់បំផុតលើភាពខ្លាំង និងបញ្ហាប្រឈម ដែលតម្រូវឱ្យបន្តដោះស្រាយដោយភាពហ្មត់ចត់ នៅដំណាក់កាលបន្ទាប់ក្នុងការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រ សម្រាប់អាជ្ញាធរទន្លេសាប និងផែនការសកម្មភាពប្រចាំឆ្នាំ២០២៦ របស់អាជ្ញាធរទន្លេសាប ដើម្បីអនុលោមតាមស្មារតីនៃបេសកកម្មការងារក្នុងការសម្របសម្រួល ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយចីរភាព។ ជាពិសេសចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដើម្បី **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** សំដៅការពារ ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។

ក្នុងស្មារតីនេះ អាជ្ញាធរទន្លេសាប បានរៀបចំកសាង និងដាក់ចេញនូវផែនការសកម្មភាពប្រចាំឆ្នាំ២០២៦ និងផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ (២០២៤-២០២៨)ជាមូលដ្ឋាន ដោយយោងលើកត្តាចាំបាច់ក្នុងបរិយាកាសសំខាន់ៗ ដូចខាងក្រោម៖

១. ការបន្តពង្រឹង និងពង្រីកសមិទ្ធផលការងារ ដែលអាជ្ញាធរទន្លេសាប សម្រេចបាននៅក្នុងដំណាក់កាលកន្លងមក ក្នុងក្របខ័ណ្ឌបេសកកម្មការងារដូចបានកំណត់ក្នុងបទដ្ឋានគតិយុត្ត និងដំណើរការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរទន្លេសាប។

២. ការបន្តកែលម្អ និងអភិបាលកិច្ចការងាររបស់អង្គភាព ឱ្យសម្រេចបាននូវប្រព័ន្ធគ្រប់គ្រងការងារប្រកបដោយប្រសិទ្ធភាពក្នុងទិដ្ឋភាពសុខដុមនីយកម្មផ្ទៃក្នុងការងារ និងកិច្ចសហប្រតិបត្តិការបណ្ដាដៃគូខាងក្រៅ ទាំងការដឹកនាំ ការសម្របសម្រួល ការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារប្រចាំថ្ងៃ គោលនយោបាយ និងយុទ្ធសាស្ត្រនានា។

៣. ការបន្តកសាង និងពង្រឹងមូលដ្ឋានដ៏រឹងមាំរបស់អាជ្ញាធរទន្លេសាប ក្នុងការយកចិត្តទុកដាក់ ជំរុញការលើកទឹកចិត្ត និងពង្រឹងការកសាងធនធានមនុស្សឱ្យបានគ្រប់ជ្រុងជ្រោយ តាមរយៈការគិតគូរដល់មន្ត្រីបន្តវេន និងកសាងសមត្ថភាពចំណេះដឹង ជំនាញ លើកិច្ចការសិក្សាស្រាវជ្រាវ ការធ្វើវិភាគ ពិសោធន៍ ការរៀបចំចងក្រងសរសេររបាយការណ៍បច្ចេកទេស ការគ្រប់គ្រងព័ត៌មាន ទិន្នន័យ ការប្រាស្រ័យទាក់ទង ការតាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃដំណើរការការងារ និងការអនុវត្តកម្មវិធី/គម្រោង ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយរបស់អង្គភាព ដើម្បីបន្តការកែលម្អឱ្យបានកាន់តែប្រសើរឡើង ស្របតាមបរិការណ៍សង្គមឌីជីថល។

៤. ការបន្តពង្រឹងអនុវត្តការសិក្សាស្រាវជ្រាវ និងសិក្សាស្វែងយល់ពីព័ត៌មាន ទិន្នន័យដែលមានលក្ខណៈវិទ្យាសាស្ត្រស្របតាមបរិបទបច្ចេកវិទ្យាថ្មីសង្គមឌីជីថល ដើម្បីធ្វើជាមូលដ្ឋានដ៏រឹងមាំសម្រាប់ធ្វើការវិភាគក្នុងការរៀបចំកសាងឯកសារបច្ចេកទេស កម្មវិធី/គម្រោងសកម្មភាព គោលនយោបាយ ផែនការ យុទ្ធសាស្ត្រពាក់ព័ន្ធ ដែលជាអាទិភាពការងារស្នូលរបស់អាជ្ញាធរទន្លេសាប រួមមាន៖ របាយការណ៍ស្ថានភាពអាងបឹងទន្លេសាប ការរៀបចំផែនទីតំបន់ទន្លេសាប គោលនយោបាយ/ផែនការយុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប ការគ្រប់គ្រងធនធានទឹកចម្រុះអាងបឹងទន្លេសាប និងផែនការចង្អុល/ផែនការមេសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប យុទ្ធសាស្ត្រគ្រប់គ្រងសហគមន៍តំបន់បឹងទន្លេសាបបន្សាំជាមួយបម្រែបម្រួលអាកាសធាតុ សម្រាប់ជំរុញប្រសិទ្ធភាពដល់ការសម្របសម្រួល និងលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយក្នុងតំបន់ និងអន្តរជាតិ ដើម្បីចូលរួមលើកកម្ពស់ដល់ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមតំបន់បឹងទន្លេសាប ប្រកបដោយចីរភាព។

៥. ការបន្តលើកកម្ពស់ប្រសិទ្ធភាពការងារប្រព័ន្ធគ្រប់គ្រងព័ត៌មាន ទិន្នន័យ បណ្ដាញផ្សព្វផ្សាយ និងចែករំលែកព័ត៌មានចំណេះដឹងឱ្យបានកាន់តែខ្លាំងក្លា តាមរយៈនៃការពង្រឹងការយកចិត្តទុកដាក់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន ការប្រាស្រ័យ

ទាក់ទង និងបច្ចេកវិទ្យា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារស្នូលរបស់អង្គភាពឱ្យកាន់តែមានភាពរឹងមាំ ស្របនឹងបច្ចេកវិទ្យាថ្មីៗក្នុងសង្គមឌីជីថល។

៦. ការបន្តពង្រឹងភាពជាដៃគូ និងជំរុញកិច្ចសហប្រតិបត្តិការទាំងក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ ដើម្បីកៀរគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការចូលរួមលើកកម្ពស់អភិបាលកិច្ចដំណើរការការងារ និងចូលរួមគាំទ្រការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការអភិវឌ្ឍនសេដ្ឋកិច្ចសង្គមតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។

ក្នុងស្មារតីបន្តរៀបចំ និងអនុវត្តន៍នូវផែនការសកម្មភាពប្រចាំឆ្នាំ ២០២៥ នេះ អាជ្ញាធរទន្លេសាប បានសម្លឹងឃើញនូវគោលបំណង និងកម្មវត្ថុច្បាស់លាស់ ក្នុងការជំរុញកិច្ចការស្នូលរបស់អង្គភាព ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅការពារ ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាន ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។

កត្តានៃការសម្លឹងឆ្ពោះទៅអនាគតរបស់ អាជ្ញាធរទន្លេសាប រួមមាន ៖

១. អាជ្ញាធរទន្លេសាប ជាអង្គភាពប្រមូលផ្តុំ ឬកន្លែងផ្ទុកដោយព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងតំបន់បឹងទន្លេសាប (Tonle Sap Information/Data Bank) ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ និងអាចទុកចិត្តបាន សម្រាប់អ្នកស្រាវជ្រាវ អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នករៀបចំគោលនយោបាយ យកទៅប្រើប្រាស់ និងវិភាគតាមតម្រូវការ។

២. អាជ្ញាធរទន្លេសាប ជាអង្គភាពប្រមូលផ្តុំ ពូនជ្រុំនូវធនធានមនុស្ស ដែលប្រកបដោយចំណេះដឹង និងជំនាញច្បាស់លាស់ លើការសិក្សាស្រាវជ្រាវ និងវិភាគមានលក្ខណៈវិទ្យាសាស្ត្រ ដែលមានការវិវត្តន៍ទៅតាមបរិបទសង្គមឌីជីថល ដើម្បីជួយលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងអង្គភាព និងសង្គមជាតិ។

៣. អាជ្ញាធរទន្លេសាប ជាអង្គភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងប្រកបដោយគុណតម្លៃ ដែលជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាល ក្នុងការគិតគូរដោយហ្មត់ចត់លើការរក្សាបាននូវតុល្យភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិតំបន់បឹងទន្លេសាបប្រកបដោយនិរន្តរភាព ហើយក៏នឹងក្លាយជាដៃគូដ៏សំខាន់ជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងកម្រិតជាតិ តំបន់ និងអន្តរជាតិ។

៤. អាជ្ញាធរទន្លេសាប ជាអង្គភាពប្រកបដោយឧត្តមភាពការងារ ក្នុងការសម្របសម្រួលដល់ការគ្រប់គ្រងធនធានទឹក បរិស្ថាន និងធនធានធម្មជាតិក្នុងតំបន់អាង/បឹងទន្លេសាប ស្របតាមគោលការណ៍ដែលបានកំណត់ក្នុងក្របខ័ណ្ឌអភិក្រមគ្រប់គ្រងអាងទន្លេ (River Basin Management Approach) និងក្លាយជាដៃគូយ៉ាងជិតស្និទ្ធជាមួយបណ្តាប្រទេសដែលជាសមាជិកអង្គការអាងទន្លេ (River Basin Organization)។

អាជ្ញាធរទន្លេសាប


Website: https://tonlesap.gov.kh

Facebook: https://www.facebook.com/TSA.MOWRAM

Telegram: https://t.me/TonleSap_Authority

YOUTUBE: https://www.youtube.com/@TonleSapAuthority

Twitter: https://twitter.com/tonle_sap